ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...........សហវ.......

# ប្រកាស
## ស្តីពី
## ការតែងតាំងប្រធាន អនុប្រធាន និងសមាជិក នៃក្រុមប្រឹក្សាភិបាល អាណត្តិទី៦ របស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៨៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគណនេយ្យ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី០២ សីហា ឆ្នាំ២០១៩ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ

**ស ម្រេ ច**

**ប្រការ ១.-**

ត្រូវបានតែងតាំងប្រធាន អនុប្រធាន និងសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) អាណត្តិទី ៦ ដូចមានរាយនាមខាងក្រោម÷

| | | |
|---|---|---|
| ១. | លោក **សាយ សុខខេង** | ប្រធាន |
| ២. | លោក **ស៊ឹម ចាន់គីរីវត្ត** | អនុប្រធាន |
| ៣. | ឯកឧត្តម **ម៉ូ ថារិន** | សមាជិក |
| ៤. | លោក **ហុង ពិសិដ្ឋ** | ហេរញ្ញិក |
| ៥. | លោកស្រី **ហាងស្រូផាត ម៉ូលីហ្សាណា** | សមាជិក |
| ៦. | លោក **ខាវ ហុង** | សមាជិក |
| ៧. | លោក **ឃុន ដារិទ្ធ** | សមាជិក |
| ៨. | លោក **វឿន ប៊ុនហេង** | សមាជិក |
| ៩. | លោក **សុខ គន្ធល** | សមាជិក |
| ១០. | លោកស្រី **ស៊ុន គីមហ៊ីន** | សមាជិក |
| ១១. | លោក **អ៊ុំ គីមសុភ័ត្រា** | សមាជិក |
| ១២. | លោក **ឡុង បូរិន្ទ** | សមាជិក |
| ១៣. | លោកបណ្ឌិត **យាន ឫទ្ធី** | សមាជិក |
| ១៤. | លោក **លី ប៊ុនសោម** | សមាជិក |
| ១៥. | លោក **អ៊ុន មាត្រា** | សមាជិក |
| ១៦. | លោកស្រី **ថៃ សុខផល្លីន** | សមាជិក |
| ១៧. | លោកស្រី **សាឌុន ដាលី** | សមាជិក និងជាលេខាធិការ ។ |

**ប្រការ ២.-**

អាណត្តិទី ៦ របស់ប្រធាន អនុប្រធាន និងសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ **វ.គ.ស.ក.** មានរយៈពេល ៤ (បួន) ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ៣.-**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៤.-**

ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ជ.គ.** ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគ្រប់ស្ថាប័នដែលពាក់ព័ន្ធ សាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ខែ ភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**<u>ចម្លងជូន៖</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ

  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៤

  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ